បន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៧

Situation Room on Cambodian Commune Council Election in 2017

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

ក្រុមអង្គការសង្គមស៊ីវិល សមាគម មិនមែនរដ្ឋាភិបាលនៅកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន រួមទាំងស្ថាប័នរដ្ឋ អង្គការជាតិ អន្តរជាតិ និងអ្នកសារព័ត៌មាន មេត្តាជ្រាបថា **យើងខ្ញុំនឹងចាប់ផ្តើមដំណើរការ បន្ទប់ស្ថានការណ៍សម្រាប់ការបោះឆ្នោតឆ្នាំ២០១៧ ចាប់ពីពេលនេះតទៅ រហូតដល់ខែកក្កដា ឆ្នាំ២០១៧។**

**បន្ទប់ស្ថានការណ៍ស្តីពីការបោះឆ្នោតឆ្នាំ២០១៧** គឺជាការប្រមូលផ្តុំនៃសមាជិកសម្ព័ន្ធកំណែទម្រង់ការបោះ ឆ្នោត អង្គការសង្គមស៊ីវិលឯករាជ្យ និងអ្នកជំនាញដើម្បី៖

- ⇒ ប្រមូលផ្តុំធនធានដើម្បីបង្កើនសមត្ថភាព និងការរួមចំនែកសហការណ៍ជាមូលនិធិ ឬគាំទ្រដើម្បីដំណើរការផែនការដាក់ពង្រាយអ្នកសង្កេតការណ៍ក្នុងស្រុកនៅថ្ងៃបោះឆ្នោត។
- ⇒ ផ្តល់ជាវេទិការនៃការសហការណ៍គ្នាដែលអាចឲ្យមានការចែករំលែក និងធ្វើបច្ចុប្បន្នភាពព័ត៌មាន បង្កើតឲ្យមានការសិក្សាវាយតម្លៃ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត ព្រមទាំងធ្វើការអន្តរាគមន៍ភ្លាមៗចំពោះបញ្ហា និងហានិភ័យនៃភាពអសន្តិសុខ ការយាយីនានាដែលទាក់ទងស្ថានភាពបោះឆ្នោត។

**ការចាប់ផ្តើមដំណើរការ**
**បន្ទប់ស្ថានការណ៍**
**ស្តីពី**
**ការបោះឆ្នោតជ្រើសរើស**
**ក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ**
**២០១៧!!**

*សេចក្តីជូនដំណឹងនេះ ចាត់ទុកជាព័ត៌មាន និងអញ្ជើញលោកអ្នក ពីបន្ទប់ស្ថានការណ៍ ដើម្បីចូលរួម តាមដាន និងយកព័ត៌មានអំពីស្ថានភាពនៃដំណើរការបោះឆ្នោត តាមរយៈបន្ទប់ស្ថានការណ៍ក្នុងពេលឆាប់ៗនេះ។*



លោកអ្នកអាចធ្វើការទាក់ទង និងយកព័ត៌មានតាមរយៈមធ្យោបាយដូចខាងក្រោម៖

* គេហទំព័របន្ទប់ស្ថានការណ៍៖ www.cambodianvotervoice.org
និងគេហទំព័រហ្វេសប៊ុក www.facebook.com/cambodianvotervoice.org
* អ៊ីម៉ែលបន្ទប់ស្ថានការណ៍ ៖ GFsituationroom@gmail.com
* លេខទំនាក់ទំនងផ្តល់មូលនិធិ ៖ 077 /015 300 760 ឬ 071 6300 760

អង្គការ សមាគម បុគ្គលឯករាជ្យ ប្រមាណជា៤០ស្ថាប័ន/នាក់ ដោយក្នុងនោះសមាជិកស្នូលនៃបន្ទប់ស្ថានការណ៍មាន៖ COMFREL, NICFEC, ADHOC, LICADHO, CLEC, SILAKA, YRDP, KYSD, PDP-Center, CCFC, CENTRAL, STT, CCIM, CYN and IMNSJ.